00280991

នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**Declassified to Public**
**12 April 2013**

**សំណុំរឿងលេខ:** ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក-ស.ច.ស

**បញ្ជូនទៅ:** សហចៅក្រមស៊ើបអង្កេត

**កាលបរិច្ឆេទនៃការបញ្ជូន** ថ្ងៃទី១១ ខែ កុម្ភៈ ឆ្នាំ២០០៩

**ភាគីបញ្ជូន:** **មេធាវីការពារអ្នកស្រី អៀង ធីរិទ្ធ**

**ភាសាដើម:** អង់គ្លេស និង ខ្មែរ (អត្ថបទបកប្រែ)

**ប្រភេទឯកសារ:** សាធារណៈ

---

## សំណើរបស់មេធាវីការពារស្នើសុំច្រានចោលភស្តុតាង ដែលបានមកដោយការធ្វើទារុណកម្ម

---

<u>បញ្ជូនដោយ៖</u>

**សហមេធាវីការពារអ្នកស្រី អៀង ធីរិទ្ធ**

លោកមេធាវី ផាត់ ពៅស៊ាង

កញ្ញា Diana ELLIS QC

**ឯកសារដើម**
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 11 / FEB / 2009
ម៉ោង (Time/Heure): 14:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fly

**ឯកសារបានចំលងត្រឹមត្រូវតាមច្បាប់ដើម**
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 12 / FEB / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fly

<u>អ្នកទទួលឯកសារ:</u>

**សហចៅក្រមស៊ើបអង្កេត**

លោក យូ ប៊ុនឡេង

លោក Marcel Lemond

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Robert PETIT

**មេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ហុង គឹមសួន

លោក ឡោ ជុនធី

លោក នី ចាន់ឌី

លោក គង់ ពិសី

Silke Studzinsky

លោក យ៉ុង ផានីត

លោក គឹម ម៉េងឃី

Martine JACQUIN

## I. សេចក្តីផ្តើម និង អំណះអំណាងសង្ខេប

1. សូមស្នើថា រាល់ភស្តុតាងនៅក្នុងសំណុំរឿងលេខ ០០២ ដែលដាក់ដោយការិយាល័យសហព្រះរាជអាជ្ញា (ហៅថា "ក.ស.ព" និង ការិយាល័យសហចៅក្រមស៊ើបអង្កេត (ហៅថា "ក.ស.ច.ស") ដែលបានមកពីលទ្ធផលនៃការធ្វើទារុណកម្ម ត្រូវតែសម្រេចថាមិនអាចទទួលយកបាន និងមិនត្រូវពិចារណានៅក្នុងដំណើរការនីតិវិធីនោះឡើយ ។ លោក អារីស្តូត បានទទួលស្គាល់កាលពី ២០០០ ឆ្នាំមុនថា ព័ត៌មានដែលបានមកពីការធ្វើទារុណកម្ម ជាញឹកញាប់មានទំនាក់ទំនងតិចតួចជាមួយការពិត។ ភស្តុតាងដែលទទួលបានតាមមធ្យោបាយនេះ ត្រូវបានពិពណ៌នាយ៉ាងត្រឹមត្រូវថាជាភស្តុតាងដែលត្រូវបានប្រឡូកប្រឡាក ហើយអាស្រ័យហេតុនេះ ភស្តុតាងនេះមិនអាចឲ្យជឿទុកចិត្តបានឡើយ។ យើងខ្ញុំសូមបង្ហាញនៅខាងក្រោមនេះ នូវក្របខ័ណ្ឌច្បាប់ជាតិ និងអន្តរជាតិដែលហាមឃាត់ការធ្វើទារុណកម្មដែលជាផ្នែកមួយនៃដំណើរការយកចម្លើយ និងហាមឃាត់បន្ថែមទៀតពីការប្រើប្រាស់ព័ត៌មានដែលបានមកពីការធ្វើទារុណកម្ម។ យើងខ្ញុំសំណូមពរថា ក្នុងការទទួលស្គាល់ឥរិយាបថខាងសីលធម៌ដ៏គួរឲ្យស្អប់ខ្ពើមរបស់អ្នកប្រព្រឹត្តអំពើទារុណកម្ម និង បំរាមស្តីពីការប្រើប្រាស់ព័ត៌មានដែលបញ្ជាក់ពីលទ្ធផលនៃអំពើមួយ សហចៅក្រមស៊ើបអង្កេត ត្រូវច្រានចោលការពិចារណានូវភស្តុតាងណាមួយដែលទទួលបាន ឬដែលអាចទទួលបានមកពីការធ្វើទារុណកម្ម នៅក្នុងអំឡុងពេលស៊ើបសួររបស់ខ្លួន ។

2. ក.ស.ច.ស គ្រប់គ្រងសម្ភារៈភស្តុតាងនៅក្នុងសំណុំរឿង ដែលអាចបង្ហាញថា ភស្តុតាងទាំងនោះបានមកពីលទ្ធផលនៃការធ្វើទារុណកម្ម[1]។ ឧទាហរណ៍ នៅក្នុងកំណត់ហេតុយកចម្លើយរបស់ឌុចជាច្រើន ឌុច បាននិយាយអំពីវិធីសាស្ត្រយកចម្លើយសារភាព និង ព័ត៌មាននៅមណ្ឌលសន្តិសុខនានា។ សៀវភៅរបស់លោក David Chandler ក្រោមចំណងជើងថា "សម្លេងពីមន្ទីរ ស-២១" (Voice from S-21) ផ្តល់ការវាយតម្លៃដែលអាចជឿទុកចិត្តបានលើវិធីសាស្ត្រដែលត្រូវបានប្រើប្រាស់ដើម្បីចម្រាញ់យកព័ត៌មាន ។

3. សារណានេះ គឺធ្វើឡើងស្របតាមបទប្បញ្ញត្តិនៃវិធាន ៥៥(១០) នៃវិធានផ្ទៃក្នុង ដែលចែងថា នៅគ្រប់ពេលវេលានៃការស៊ើបសួរ ជនត្រូវចោទ ឬ ដើមបណ្តឹងរដ្ឋប្បវេណីអាចស្នើសុំឲ្យសហចៅក្រមស៊ើបអង្កេតចេញដីកា ឬ បំពេញកិច្ចស៊ើបសួរណាមួយដែលខ្លួនយល់ឃើញថា មានប្រយោជន៍ដល់ការស៊ើបសួរ។

---

[1] សូមមើល ការយកចម្លើយ ឌុច ដោយសហចៅក្រមស៊ើបអង្កេត ជាពិសេស ឯកសារលេខ D86-D90 ក្នុងសំណុំរឿងលេខ ០០២ ។

4. នៅក្នុងដំណាក់កាលនេះនៃដំណើរការនីតិវិធី ភស្តុតាងដែលទទួលបានមកពីការធ្វើទារុណកម្ម អាចត្រូវបានប្រើប្រាស់ជាភស្តុតាងតម្រុយដើម្បីចម្រាញ់យកព័ត៌មានសម្រាប់កិច្ចស៊ើបសួរបន្តទៀត ហើយខ្លឹមសាររបស់វា ក៏អាចត្រូវបានប្រើប្រាស់ក្នុងការសម្រេចលើបទចោទប្រកាន់ស្ថាពរប្រឆាំងនឹងអ្នកស្រី អៀង ធីរិទ្ធ ផងដែរ ។ មេធាវីការពារសូមជំទាស់ទម្រង់នៃភស្តុតាងទាំងពីរនេះ។

5. កិច្ចស៊ើបសួរប្រឆាំងនឹង ឌុច ត្រូវបានបញ្ចប់ ហើយកិច្ចស៊ើបសួរប្រឆាំងនឹងអ្នកស្រី អៀង ធីរិទ្ធ ទើបតែបានចាប់ផ្តើមតែប៉ុណ្ណោះ។ មេធាវីការពារសូមស្នើថា វាជាការចាំបាច់ដែលបញ្ហានេះត្រូវបានដោះស្រាយនៅដំណាក់កាលនៃដំណើរការនីតិវិធីនេះ ធ្វើយ៉ាងដូច្នេះ វាអាចបញ្ជាក់ពីគោលជំហររបស់អង្គជំនុំជម្រះវិសាមញ្ញ ស្តីពីការប្រើប្រាស់ភស្តុតាងបែបនេះ នៅពេលដែលកិច្ចស៊ើបសួរកំពុងតែបន្ត ។

## II. អង្គហេតុពាក់ព័ន្ធ

6. ចាប់តាំងពីថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០០៨ ជារបួតមក កំណត់ហេតុយកចម្លើយ ឌុច ដោយ ក.ស.ច.ស នៅក្នុងសំណុំរឿងលេខ ០០១ បានបញ្ចូលទៅក្នុងសំណុំរឿងលេខ ០០២[2]។ ការយកចម្លើយបាននេះ បញ្ជាក់ពីគោលជំហររបស់ ឌុច ដែលបង្ហាញថា ចម្លើយសារភាពនៅមន្ទីរសន្តិសុខ ស-២១ បានមកពីការធ្វើទារុណកម្ម[3] ហើយថា មន្ទីរសន្តិសុខដទៃទៀតបានអនុវត្តការធ្វើទារុណកម្មស្រដៀងគ្នានេះផងដែរ[4]។

7. នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ក.ស.ព បានយោងចម្លើយសារភាពជាច្រើន និងឯកសារសំខាន់ៗមួយចំនួន ដែលបានមកពីការធ្វើទារុណកម្ម[5] ហើយក៏ពឹងផ្អែកទៅលើឯកសារជា

---

[2] ករណីព្រះរាជអាជ្ញា តទល់ជាមួយ នួន ជា និងអ្នកផ្សេងទៀត, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក--អ.ប.ជ(០២), កំណត់ហេតុជាលាយលក្ខអក្សរនៃសវនាការតទល់ កាលពីថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧, ឯកសារលេខ D.86/1 ដាក់នៅក្រឡាបញ្ជីនៅថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០០៨ (ERN 00145454-00145457) ។

[3] សូមមើល ឧទាហរណ៍ កំណត់ហេតុយកចម្លើយជនត្រូវចោទជាលាយលក្ខណ៍អក្សរ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០០៧ ឯកសារ D86/3 (ERN 000147517-000147527) ទំព័រ ៨ ។ កំណត់ហេតុយកចម្លើយជនត្រូវចោទជាលាយលក្ខណ៍អក្សរ ចុះថ្ងៃទី២ ខែតុលា ឆ្នាំ២០០៧ ឯកសារលេខ D86/6 (ERN 000147600-000147608) ទំព័រ ៦ ។ល។

[4] សូមមើល ឧទាហរណ៍ កំណត់ហេតុយកចម្លើយជនត្រូវចោទជាលាយលក្ខណ៍អក្សរ ចុះថ្ងៃទី២ ខែមិថុនា ឆ្នាំ២០០៧ ឯកសារ D87 (ERN 00195571-00195579) ទំព័រ៤ ដែលក្នុងនោះ ឌុច បាននិយាយថា "គណៈអចិន្ត្រៃយ៍ទាំងមូលបានដឹងថាទារុណកម្មត្រូវបានអនុវត្តនៅគ្រប់មន្ទីរសន្តិសុខទាំងអស់"។

[5] សូមមើល ឧទាហរណ៍ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យទៅស៊ើបសួរអក្សរក្នុងលេខយោង 80, 82, 119, 177-180, 182, 183, 203, 216, 327, 335, 337, 340, 342, 344, 345, 350, 355-357, 375, 376, 384, 391-394, 398-400, 410, 416, 417, 419,

ច្រើន ដែលឯកសារទាំងនោះបានយោងទៅលើភស្តុតាងបានមកពីការធ្វើទារុណកម្ម ដូចជា សៀវភៅរបស់លោក Stephen Heder "ជនប្រាំពីរនាក់ប្រឈមមុខនឹងការកាត់ទោស (Seven Candidates for Prosecution)"[6] និង លោក David Chandler, Ben Kiernan និង Chanthou Boua ក្រោមចំណងជើងថា "ប៉ុល ពត ធ្វើផែនការសម្រាប់អនាគត" (Pol Pot Plans the Future)[7]។ បន្ថែមពីលើនេះ ឯកសារផ្សេងៗទៀតដែលប្រើប្រាស់ដោយ ក.ស.ព បានយោងទៅលើប្រភពបន្ទាប់បន្សំតែប៉ុណ្ណោះ[8]។ អាស្រ័យហេតុនេះ ក.ស.ព បានប្រើប្រាស់ភស្តុតាងជាច្រើននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ខ្លួន ដែលយោងទៅលើតែភស្តុតាងដែលបានមកពីការធ្វើទារុណកម្ម ។

8. មេធាវីការពារសូមស្នើថា ការប្រើសម្ភារៈភស្តុតាងដែលបានមកដោយខុសច្បាប់បែបនេះ គឺមិនអាចទទួលយកបានទេ នៅក្នុងដំណើរការនីតិវិធីបច្ចុប្បន្ននេះ ដោយសារតែ វារំលោភបទប្បញ្ញត្តិនៃច្បាប់ជាតិ និង អន្តរជាតិ។ បន្ថែមពីលើនេះ វារំលោភសិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ និង ការសន្មត់ទុកជាមុនថាគ្មានទោស។ នៅក្នុងកាលៈទេសៈបែបនេះ មេធាវីការពារ យល់ឃើញថា ក.ស.ច.ស គប្បីបញ្ឈប់ការប្រើប្រាស់សម្ភារៈភស្តុតាងបែបនេះ ។

## III. បទដ្ឋានគតិយុត្តពាក់ព័ន្ធ និង ការបកស្រាយបទដ្ឋានគតិយុត្ត

### ៣.១ ច្បាប់កម្ពុជា

9. មាត្រា៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា ចែងថា "ការទទួលសារភាពដែលកើតឡើងពីការបង្ខិតបង្ខំតាមផ្លូវកាយក្តី តាមផ្លូវចិត្តក្តី មិនត្រូវទុកជាភស្តុតាងនៃពិរុទ្ធភាពទេ។ វិមតិសង្ស័យ ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ"។ ស្រដៀងគ្នានេះដែរ មាត្រា ២៤(៣)នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលអ៊ុនតាក់ ឆ្នាំ១៩៩២ ដែលនៅជាធរមាននៅឡើយ ចែងថា "បណ្តាពាក្យសារភាពរបស់ជនជាប់ចោទទាំងឡាយដែលបានមកពីការបង្ខិតបង្ខំ តាមបែបណាក៏ដោយ ត្រូវចាត់ទុកជាមោឃៈ" ។ មាត្រា ៣២១ នៃ

---

420, 425, 427, 429, 432, 433, 457-463, 465-467, 490, 519, 520, 528, 530-533, 537-539, 541, 552, 555, 558, 564 និង លេខយោង 566 ។

[6] Stephen Heder និង Brian D. Tittemore "ជនប្រាំពីរនាក់ប្រឈមមុខនឹងការកាត់ទោស, ការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម" ភ្នំពេញ: DC-Cam 2004 ទំព័រ ២៩ ដល់ ៣១ ។

[7] David Chandler, Ben Kiernan និង Chanthou Boua's "ប៉ុល ពត ធ្វើផែនការសម្រាប់អនាគត់ ។ ឯកសារសំងាត់របស់កម្ពុជាប្រជាធិបតេយ្យ" ។ សូមមើលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យទៅស៊ើបសួរ ទំព័រ ១០៦ លេខយោង ៨០ ។

[8] សូមមើល ឧទាហរណ៍ គ្រាន់តែជាមធ្យោបាយផ្តល់ជាឧទាហរណ៍: កាសែតភ្នំពេញប៉ុស (១៦/១) "បងធំទី២នៃ Amnesia" លេខចេញផ្សាយ ថ្ងៃទី ១២-២៥ ខែមករា ឆ្នាំ២០០៧ (ERN 00081516-00081520)។

ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចែងកាន់តែច្បាស់ថា "ការសារភាព ក៏ដូចជាប្រភេទនៃភស្តុតាងដទៃទៀតដែរ ត្រូវដាក់ជូនតុលាការធ្វើការថ្លឹងថ្លែង។ ចម្លើយសារភាពដែលទទួលបានក្រោមការបង្ខិតបង្ខំខាងរូបកាយ ឬខាងផ្លូវចិត្តនេះ គ្មានតំលៃជាភស្តុតាងបានឡើយ" ។

10. ហេតុដូច្នេះ ច្បាប់កម្ពុជាបានបញ្ញត្តិយ៉ាងច្បាស់នៅក្នុងការច្រានចោលភស្តុតាងដែលទទួលបានក្រោមការធ្វើទារុណកម្ម ហើយក្នុងករណីមានវិមតិសង្ស័យ ត្រូវបានដោះស្រាយជាប្រយោជន៏ដល់ជនជាប់ចោទ។

11. ប្រទេសកម្ពុជា បានផ្តល់សច្ចាប័នលើអនុសញ្ញាប្រឆាំងនឹងទារុណកម្មនៅឆ្នាំ ១៩៩២ ។

## ៣.២ <u>វិធានផ្ទៃក្នុងរបស់ អ.វ.ត.ក</u>

12. វិធាន ៨៧(១) នៃវិធានផ្ទៃក្នុងចែងថា "លើកលែងតែមានបទប្បញ្ញត្តិផ្សេងក្នុងវិធានផ្ទៃក្នុងនេះ រាល់ភស្តុតាងទាំងអស់ត្រូវតែទទួលយក"។ វិធាន៨៧(២)(ឃ)ចែងថា អង្គជំនុំជម្រះអាចបដិសេធចំពោះពាក្យសុំឲ្យពិនិត្យភស្តុតាង បើយល់ឃើញថា "ច្បាប់មិនអនុញ្ញាត"។

13. វិធាន ៨៧(១) អាចត្រូវគេយល់ថា ជាវិធានទូទៅ (*lex generalis*) ។ បទប្បញ្ញត្តិនៃមាត្រា១៥ នៃអនុសញ្ញាប្រឆាំងនឹងទារុណកម្ម ("CAT") ចែងអំពីការច្រានចោលនូវភស្តុតាងដែលជិតដាមដោយអំពីទារុណកម្ម អាចត្រូវបានគេយល់ថា ជាវិធានទូទៅ ដែលផ្តល់នូវស្ថានភាពមួយកាន់តែច្បាស់ជាងវិធានផ្ទៃក្នុង។ វិធានពិសេស (*lex specialis*) មានអានុភាពលើវិធានទូទៅ (*lex generalis*) ហើយ វិធាន ១៥ នៃអនុសញ្ញាប្រឆាំងនឹងទារុណកម្ម ត្រូវតែបានពិចារណាដោយ អ.វ.ត.ក ។ មាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងទារុណកម្ម ក៏ស្របជាមួយវិធាន ៨៧(២)(ឃ) នៃវិធានផ្ទៃក្នុងផងដែរ។

14. សំខាន់ជាងនេះទៅទៀត វិធាននីតិវិធីរបស់ អ.វ.ត.ក មិនមានប្រៀបលើកាតព្វកិច្ចរបស់កម្ពុជាក្រោមច្បាប់អន្តរជាតិនោះទេ។ តុលាការកម្ពុជា និងអង្គជំនុំជម្រះវិសាមញ្ញ ត្រូវជាប់កាតព្វកិច្ចទៅនឹងសន្ធិសញ្ញាទាំងឡាយដែលចុះហត្ថលេខាដោយរដ្ឋាភិបាលកម្ពុជា។ ហេតុដូច្នេះ ចៅក្រមនៅ អ.វ.ត.ក ត្រូវជាប់កាតព្វកិច្ចទៅនឹងមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងទារុណកម្មផងដែរ។

## ៣.៣ <u>តុលាការព្រហ្មទណ្ឌអន្តរជាតិផ្សេងទៀត</u>

15. មាត្រា ២៣ ថ្មីនៃច្បាប់បង្កើត អ.វ.ត.ក ចែងថា:

"ប្រសិនបើនីតិវិធីដែលមានស្រាប់ពុំមានចែងពីករណីពិសេសណាមួយ ឬ ប្រសិនបើមានភាពមិនច្បាស់លាស់ក្នុងការបកស្រាយ ឬ អនុវត្តនីតិវិធីនោះ ប្រសិនបើមានបញ្ហាទាក់ទងទៅនឹងភាពសមស្របនៃនីតិ

វិធីទាំងនេះជាមួយបទដ្ឋានអន្តរជាតិ សហចៅក្រមស៊ើបអង្កេតអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធី ដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ" ។

16. អាស្រ័យហេតុនេះ គេត្រូវស្វែងរកការណែនាំបន្ថែម ដោយពិនិត្យពិចារណាលើវិធាននីតិវិធីនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ហើយវិធាន៩៥ នៃវិធាននីតិវិធីរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី និង ប្រទេសរ្វាន់ដា បានបញ្ញត្តិថា:

"ភស្តុតាងនឹងមិនអាចយកជាការបានឡើយ ប្រសិនបើភស្តុតាងនោះបានមកតាមមធ្យោបាយទាំងឡាយណាដែលបង្កប់នូវវិមតិសង្ស័យជាដុំកំភួនលើភាពដែលអាចជឿទុកចិត្តបាននៃភស្តុតាង ឬការទទួលយកភស្តុតាងទំនងជាប្រឆាំងចំពោះ និងទំនងជាបង្កព្យសនកម្មយ៉ាងធ្ងន់ធ្ងរដល់សុច្ចរិតភាពនៃដំណើរការនីតិវិធី" ។

17. មាត្រា ៦៩(៧) នៃច្បាប់លក្ខន្តិកៈទីក្រុងរ៉ូម បានបញ្ញត្តិនូវវាក្យសព្ទខុសគ្នាបន្តិចដូចខាងក្រោមៈ

"ភស្តុតាងដែលបានមកតាមមធ្យោបាយរំលោភបំពានលើច្បាប់លក្ខន្តិកៈនេះ ឬ បំពានលើសិទ្ធិមនុស្សដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ មិនត្រូវទទួលយកជាបានការឡើយ ប្រសិនបើ:

ក. ការរំលោភបំពាននាំឲ្យមានវិមតិសង្ស័យជាដុំកំភួនលើភាពដែលអាចជឿទុកចិត្តបាននៃភស្តុតាង ឬ

ខ. ការទទួលយកភស្តុតាងទំនងជាប្រឆាំងដល់ និងទំនងជាបង្កព្យសនកម្មយ៉ាងធ្ងន់ធ្ងរដល់សុច្ចចរិតភាពនៃដំណើរការនីតិវិធី" ។

18. មេធាវីការពារមិនបានដឹងពីករណីណាមួយ ដែលតុលាការព្រហ្មទណ្ឌអន្តរជាតិមួយក្នុងចំណោមតុលាការព្រហ្មទណ្ឌអន្តរជាតិដទៃទៀត បានសម្រេចពីភាពយកជាបានការនៃភស្តុតាងដែលបានមកពីការធ្វើទារុណកម្មនោះឡើយ។ ប៉ុន្តែ ដោយពិចារណាលើការទទួលស្គាល់ជាទូទៅថា ព័ត៌មានដែលបានមកពីការធ្វើទារុណកម្ម គឺជាភស្តុតាងដែលមិនអាចជឿទុកចិត្តបាន និងជាភស្តុតាងដែលប្រឡូកប្រឡាក់ ហើយបទប្បញ្ញត្តិដាច់ខាតនៃវិធាន ៩៥ និងមាត្រា ៦៩(៧) ប្រសិនបើព្រះរាជអាជ្ញាណាម្នាក់ស្វែងរកនូវការសំអាងលើភស្តុតាងបែបនេះ នឹងប្រឈមជាមួយ បន្ទុកដែលមិនអាចយកឈ្នះបានឡើយ។

## ៣.៤ ច្បាប់អន្តរជាតិ: អនុសញ្ញាប្រឆាំងនឹងទារុណកម្ម [CAT]

19. មាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងទារុណកម្មចែងថា[9]÷

[9] អនុសញ្ញានេះ ត្រូវបានទទួលស្គាល់ដោយប្រទេសកម្ពុជា នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២ ។ សូមមើលឯកសារ: http://untreaty.un.org/ENGLISH/bible/englishinternetbible/partI/chapterIV/treaty14.asp.

"រដ្ឋជាភាគីត្រូវធានាថា ចម្លើយសារភាពដែលទទួលបានមកពីការធ្វើទារុណកម្ម មិនត្រូវពិចារណាថាជាភស្តុតាងនៅក្នុងដំណើរការនីតិវិធីបានឡើយ លើកលែងតែកំណត់ហេតុផ្តល់ចម្លើយនោះត្រូវយកមកសំអាងជាភស្តុតាងប្រឆាំងនឹងជនជាប់ចោទនៃអំពើទារុណកម្ម តែប៉ុណ្ណោះ"។

20. មេធាវីការពារសូមស្នើថា អត្ថបទនៃបទប្បញ្ញត្តិនេះ គឺត្រូវបានកំណត់ដោយឯកឯង ដែលក្នុងនោះការប្រើប្រាស់ភស្តុតាងដែលបានមកពីការធ្វើទារុណកម្ម ត្រូវបានកម្រិតយ៉ាងតឹងរ៉ឹងបំផុតចំពោះតែការប្រើប្រាស់សម្រាប់"ប្រឆាំងទៅលើជនដែលត្រូវចោទប្រកាន់ពីការធ្វើទារុណកម្ម នូវភស្តុតាងដែលកើតចេញពីចម្លើយសារភាព"[10] ។

21. កម្ពុជា គឺជារដ្ឋហត្ថលេខីដែលត្រូវជាប់កាតព្វកិច្ចទៅនឹងបទប្បញ្ញត្តិនៃមាត្រា ២៦ នៃអនុសញ្ញាក្រុងវីយែនឆ្នាំ១៩៦៩ ស្តីពីច្បាប់សន្ធិសញ្ញា ហើយហេតុដូច្នេះ ចៅក្រមនៅ អ.វ.ត.ក រួមទាំងសហចៅក្រមស៊ើបអង្កេត ត្រូវតែគោរពបទប្បញ្ញត្តិនេះ។ លោក Scharf បានទាញហេតុផលថា ចៅក្រមនៅ អ.វ.ត.ក មិនជាប់កាតព្វកិច្ចនឹងអនុសញ្ញានេះទេ ដោយហេតុថា អ.វ.ត.ក គឺជានីតិបុគ្គលដាច់ដោយឡែក ដែលមិនត្រូវចងភ្ជាប់ទៅនឹងកាតព្វកិច្ចច្បាប់អន្តរជាតិរបស់កម្ពុជានោះឡើយ។ ប៉ុន្តែគាត់ទទួលស្គាល់ថា កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និង រដ្ឋាភិបាលកម្ពុជា តម្រូវឱ្យ អ.វ.ត.ក "អនុវត្តយុត្តាធិការរបស់ខ្លួនស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ" ហើយគាត់ស្ទាក់ស្ទើរក្នុងការសន្និដ្ឋានថា "យ៉ាងហោចណាស់ តុលាការកម្ពុជាមិនចង់ឱ្យគេយល់ថា ខ្លួនកំពុងរំលោភលើអនុសញ្ញាប្រឆាំងនឹងទារុណកម្មយ៉ាងចំអកឡកឡឺយ ដែលនាំឱ្យអន្តរាយដល់នីត្យានុកូលភាពរបស់ខ្លួន និងការគាំទ្រពីអន្តរជាតិ"នោះទេ[11]។ លោក Thienel បានទាញហេតុផលបន្តទៀតថា ក្រៅពីច្បាប់សន្ធិសញ្ញា វាអាចត្រូវបានគេអះអាងថា "កាតព្វកិច្ចនៃមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងទារុណកម្មបានសម្រេចឋានៈជាច្បាប់ទំនៀមទម្លាប់"[12] ។

---

[10] បញ្ជាក់បន្ថែម ។

[11] M.P. Scharf, "Tainted Provenance: ប្រសិនបើអាច តើនៅពេលណាដែលភស្តុតាងនៃអំពើទារុណកម្មអាចទទួលយកបាន? When, If Ever, Should Torture Evidence Be Admissible?", in: 65 Wash & Lee L. Rev. 129 (Winter 2008), (Annex 4) at 135-136.

[12] T. Thienel "ការទទួលយកភស្តុតាងដែលបានមកពីការធ្វើទារុណកម្ម ក្រោមច្បាប់អន្តរជាតិ (The Admissibility of Evidence Obtained by Torture under International Law)០: ទិនានុប្បវត្តិនៃច្បាប់អន្តរជាតិសហភាពអឺរ៉ុបលេខ ១៧ (ឆ្នាំ២00៦) ៣៤៩, (ឧបសម្ព័ន្ធ ៧) នៅទំព័រ ៣៦៥ ។

22. បទអត្ថាធិប្បាយទូទៅលេខ ២០ ចំពោះមាត្រា ៧ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្ស និង សិទ្ធិនយោបាយ ("ICCPR") ដែលបង្ហាញដោយការិយាល័យឧត្តមស្នងការនៃអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស មានអត្ថន័យថា:

"វាមានសារៈសំខាន់ណាស់ក្នុងការមិនលើកទឹកចិត្តឱ្យរំលោភបំពានក្រោមមាត្រា ៧ ដែលចែងថា ច្បាប់ត្រូវតែហាមឃាត់ការទទួលយកនូវកំណត់ហេតុផ្តល់ចម្លើយ ឬ ចម្លើយសារភាពដែលបានមកពីការធ្វើទារុណកម្ម ឬការធ្វើប្រព្រឹត្តកម្មផ្សេងទៀតដែលច្បាប់ហាមឃាត់"[13] ។

23. នៅក្នុងរបាយការណ៍ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៣ គណៈកម្មាធិការប្រឆាំងនឹងទារុណកម្ម (ជាស្ថាប័នរបស់អង្គការសហប្រជាជាតិទទួលភារកិច្ចតាមដានអនុសញ្ញាប្រឆាំងនឹងអំពើទារុណកម្ម) បានផ្តល់អនុសាសន៍ដល់ប្រទេសកម្ពុជា[14]។ នៅក្នុងឯកសារនេះ គណៈកម្មាធិការប្រឆាំងនឹងការធ្វើទារុណកម្ម បញ្ជាក់ពីការព្រួយបារម្ភរបស់ខ្លួនអំពី "ការទទួលយកចម្លើយសារភាពនៅក្នុងដំណើរការនីតិវិធីរឿងក្តីព្រហ្មទណ្ឌ និង ការដែលនគរបាល និង តុលាការពឹងផ្អែកលើចម្លើយសារភាពដើម្បីផ្តន្ទាទោស"[15] ។ ជាពិសេស គណៈកម្មាធិការនេះបានផ្តល់ដំបូន្មានដល់កម្ពុជា "ឱ្យចាត់វិធានការដើម្បីធានាថា ភស្តុតាងដែលបានមកពីការធ្វើទារុណកម្ម មិនត្រូវលើកមកសំអាងនៅតុលាការបានឡើយ"[16] ។

24. Redress កាលពីឆ្នាំ ២០០៦ បានចេញផ្សាយនូវរបាយការណ៍ស្តីពីការអនុវត្តនៅថ្នាក់ជាតិនៃកាតព្វកិច្ចអន្តរជាតិទាក់ទងនឹងការឃាមឃាត់ការធ្វើទារុណកម្ម។ របាយការណ៍បានគូសបញ្ជាក់ពី

---

[13] ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស, បទអត្ថាធិប្បាយទូទៅលេខ ២០ ស្តីពីទារុណកម្ម, ការប្រព្រឹត្តឃោរឃៅ ឬការបន្ទាបបន្ថោក ឬការដាក់ទណ្ឌកម្ម (មាត្រា៧)০: 30/05/82 CCPR បទអត្ថាធិប្បាយទូទៅលេខ ២០ (បទអត្ថាធិប្បាយទូទៅ)URLaddress:http://www.unhchr.ch/tbs/doc.nsf/0/6924291970754969c12563ed004c8ae5? Opendocument ទំព័រ 12

[14] គណៈកម្មាធិការប្រឆាំងនឹងទារុណកម្ម, សេចក្តីសន្និដ្ឋាន និង អនុសាសន៍របស់គណៈកម្មាធិការប្រឆាំងនឹងទារុណកម្មៈ កម្ពុជា ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ ២០០៣, ឯកសារលេខCAT/C/CR/30/2(សេចក្តីសន្និដ្ឋានទៅលើការសង្កេតការណ៍/អនុសាសន៍), URL address: http://www.unhchr.ch/tbs/doc.nsf/(Symbol)/CAT.C.CR.30.2.En? Open Document.

[15] គណៈកម្មាធិការប្រឆាំងនឹងទារុណកម្ម, សេចក្តីសន្និដ្ឋាន និង អនុសាសន៍របស់គណៈកម្មាធិការប្រឆាំងនឹងទារុណកម្មៈ កម្ពុជា ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ ២០០៣, ឯកសារលេខCAT/C/CR/30/2(សេចក្តីសន្និដ្ឋានទៅលើការសង្កេតការណ៍/អនុសាសន៍), URL address: http://www.unhchr.ch/tbs/doc.nsf/(Symbol)/CAT.C.CR.30.2? Open Document, កថាខណ្ឌ 6 (h)

[16] គណៈកម្មាធិការប្រឆាំងនឹងទារុណកម្ម, សេចក្តីសន្និដ្ឋាន និង អនុសាសន៍របស់គណៈកម្មាធិការប្រឆាំងនឹងទារុណកម្មៈ កម្ពុជា ចុះថ្ងៃទី២៧ ខែឧសភា ២០០៣, ឯកសារលេខ CAT/C/CR/30/2 (សេចក្តីសន្និដ្ឋានទៅលើការសង្កេតការណ៍/អនុសាសន៍), URL address: http://www.unhchr.ch/tbs/doc.nsf/(Symbol)/CAT.C.CR.30.2? Open Document, កថាខណ្ឌ 7 (f)

បំរាមនៃមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងទារុណកម្ម និងបានបង្ហាញនូវទិដ្ឋភាពមួយចំនួននៃបំរាមទាំងនោះ។ របាយការណ៍ចែងថា "បំរាមត្រូវតែគ្មានលក្ខខណ្ឌ ដោយគ្មានការលើកលែង ហើយមិនអនុញ្ញាតឱ្យចៅក្រម និង អ្នកធ្វើសេចក្តីសម្រេចដទៃទៀតប្រើឆន្ទានុសិទ្ធថាតើត្រូវទទួលយក ឬ ត្រូវថ្លឹងថ្លែងតម្លៃភស្តុតាងបែបនេះនោះទេ"[17] ។

25. អ្នករាយការណ៍ពិសេសស្តីពីទារុណកម្ម និងការប្រព្រឹត្តឃោរឃៅដទៃទៀត, ការប្រព្រឹត្តអមនុស្សធម៌ ឬបន្ថាបបន្ថោក ឬការដាក់ទណ្ឌកម្ម បានដាក់របាយការណ៍កាលពីថ្ងៃទី១៤ ខែសីហា ឆ្នាំ ២០០៦ ទៅមហាសន្និបាតរបស់អង្គការសហប្រជាជាតិ[18]។ នៅក្នុងរបាយការណ៍នេះ មានផ្នែកមួយនិយាយអំពី "គោលការណ៍នៃការមិនទទួលយកនូវភស្តុតាងដែលបានមកពីការធ្វើទារុណកម្ម" ដោយពិពណ៌នាលំអិតនូវមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងទារុណកម្ម ។

26. ជាបឋម របាយការណ៍យោងទៅលើករណីរវាងប្រទេសអាឡឺម៉ង់ តទល់ជាមួយ *Mounir el Motassadeq*[19] ដែលតុលាការកំពូលអាឡឺម៉ង់កាលពីថ្ងៃទី ៤ ខែមីនា ឆ្នាំ២០០៤ បានច្រានចោលសេចក្តីសម្រេចរបស់តុលាការជាន់ទាប ដែលសំអាងលើភស្តុតាងទទួលបានមកពីការធ្វើទារុណកម្ម។ រឿងក្តីនេះបានបញ្ជូនទៅតុលាការ Hamburg ដើម្បីជំនុំជម្រះឡើងវិញ ដែលតុលាការនេះបានច្រានចោលភស្តុតាងដែលប្រឡូកប្រឡាក់ដោយអំពើទារុណកម្ម[20] ។ បញ្ហាដែលកើតឡើងនៅក្នុងរឿងក្តីនេះ បានបង្ហាញដោយខ្លួននូវនិយមន័យនៃបន្ទុកនៃការបង្ហាញភស្តុតាង ដែលតុលាការ Hamburg យល់ឃើញថា សក្ខីកម្មជាក់លាក់ជាច្រើនអាចទទួលយកបាន ដោយហេតុថាសច្ចភាពនៃការចោទប្រកាន់អំពីទារុណកម្ម មិនបានបង្កើតឱ្យបានពេញលេញនោះឡើយ ។ អ្នករាយការណ៍ពិសេសបានធ្វើការរិះគន់អំពីទិដ្ឋភាពនៃសេចក្តីសម្រេច ដែលចង្អុលបង្ហាញថា

---

[17] Redress Bringing the International Prohibition of Torture Home. ការអនុវត្តនៅថ្នាក់ជាតិ មគ្គុទ្ទេសសម្រាប់អនុសញ្ញារបស់អង្គការសហប្រជាជាតិប្រឆាំងនឹងទារុណកម្ម និង ការប្រព្រឹត្តឃោរឃៅដទៃទៀត, អមនុស្សធម៌ ឬ បន្ថាបបន្ថោក ឬ ការដាក់ទណ្ឌកម្ម ខែមករា ឆ្នាំ២០០៦, ទំព័រ ៦២ (ឧបសម្ព័ន្ធ ១) ។

[18] មហាសន្និបាតរបស់អង្គការសហប្រជាជាតិ, ទារុណកម្ម និង ការប្រព្រឹត្តឃោឃៅដទៃទៀត, អមនុស្សធម៌ ឬ បន្ថាបបន្ថោក ឬ ការដាក់ទណ្ឌកម្មឯកសារ UN Doc. No. A/61/259, ថ្ងៃទី១៤ ខែសីហា ឆ្នាំ ២០០៦ (ឧបសម្ព័ន្ធ២) ។

[19] *Beschluss IV – 1/04 des Hanseatischen Oberlandesgericht Hamburg,* Neue Juristische Wochenschrift 2005 Heft 32 of 14 June 2005 បានយោងនៅក្នុងមហាសន្និបាតអង្គការសហប្រជាជាតិ, ទារុណកម្ម និង ការប្រព្រឹត្តឃោរឃៅដទៃទៀត, អមនុស្សធម៌ ឬ បន្ថាបបន្ថោក ឬ ការដាក់ទណ្ឌកម្ម ឯកសារ UN Doc. No. A/61/259, ថ្ងៃទី១៤ ខែសីហា ឆ្នាំ ២០០៦ (ឧបសម្ព័ន្ធ២) កថាខណ្ឌ ៤៦។

[20] មហាសន្និបាតអង្គការសហប្រជាជាតិ, ទារុណកម្ម និង ការប្រព្រឹត្តឃោរឃៅដទៃទៀត, អមនុស្សធម៌ ឬ បន្ថាបបន្ថោក ឬ ការដាក់ទណ្ឌកម្មឯកសារ UN Doc. No. A/61/259, ថ្ងៃទី១៤ ខែសីហា ឆ្នាំ ២០០៦ (ឧបសម្ព័ន្ធ២) ទំព័រ ១១ ដល់ ១៤ ។

បន្ទុកនៃការបង្ហាញភស្តុតាង គួរតែត្រូវបានផ្ទេរទៅឱ្យអាជ្ញាធររបស់រដ្ឋាភិបាលវិញ ដែលបានសំអាងលើភស្តុតាងដែលចោទជាបញ្ហា[21] ។

27. របាយការណ៍យោងបន្តទៅលើសេចក្តីសម្រេចចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៥ លើករណី *A និងអ្នកដទៃទៀត តទល់ជាមួយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ*នៃសភាជាន់ខ្ពស់ចក្រភពអង់គ្លេស(House ofLords)[22] សភាជាន់ខ្ពស់សម្រេចជាឯកច្ឆ័ន្ទ នៅក្នុងការថ្កោលទោសរបស់ខ្លួនប្រឆាំងនឹងទារុណកម្ម និងការប្រើប្រាស់កំណត់ហេតុឆ្លើយចម្លើយ ដែលប្រឡូកប្រឡាក់ដោយអំពើទារុណកម្មនៅក្នុងដំណើរការតុលាការ។ ជាថ្មីម្តងទៀត ទាក់ទងនឹងបន្ទុកនៃការបង្ហាញភស្តុតាងនេះដែរ ពួកគេបានយកលក្ខខណ្ឌដូចគ្នានឹងតុលាការអាឡឺម៉ង់ខាងលើដែរ ដោយធ្វើការអះអាងថា ដើម្បីឱ្យមានតុល្យភាពនៃវិមតិសង្ស័យ ភស្តុតាងត្រូវតែបានច្រានចោល ប្រសិនបើភស្តុតាងដែលលើកមកសំអាងនោះ ទទួលបានមកពីការធ្វើទារុណកម្ម[23] ។

## ៣.៥ <u>ការបកស្រាយរបស់លោក Stephen Heder</u>

28. នៅក្នុងសៀវភៅ "ជនប្រាំពីរនាក់ប្រឈមមុខនឹងកាត់ទោស" របស់លោក Stephen Heder និង Brian D. Tittermore ចង្អុលបង្ហាញថា:

"ដើម្បីពឹងផ្អែកលើកំណត់ហេតុឆ្លើយចម្លើយដែលត្រូវបានផ្តល់ [ក្រោមការធ្វើទារុណកម្ម] បានកើតឡើងនូវបញ្ហាសីលធម៌ និងវិធីសាស្ត្រយ៉ាងធ្ងន់ធ្ងរ។ សញ្ញាណនៃការប្រើប្រាស់ចម្លើយសារភាពដែលត្រូវបានគេស្គាល់ថា បានមកពីលទ្ធផលនៃការធ្វើទារុណកម្ម ត្រូវបានច្រានចោលមិនឱ្យប្រើប្រាស់ស្ទើរនៅគ្រប់កាលៈទេសៈទាំងអស់"[24] ។

---

[21] មហាសន្និបាតអង្គការសហប្រជាជាតិ, ទារុណកម្ម និង ការប្រព្រឹត្តឃោរឃៅដទៃទៀត, អមនុស្សធម៌ ឬ បន្ទាបបន្ថោក ឬ ការដាក់ទណ្ឌកម្ម ឯកសារ UN Doc. No. A/61/259, ថ្ងៃទី១៤ ខែសីហា ឆ្នាំ ២០០៦ (ឧបសម្ព័ន្ធ២) ទំព័រ ១៧ ។

[22] មហាសន្និបាតអង្គការសហប្រជាជាតិ, ទារុណកម្ម និង ការប្រព្រឹត្តឃោរឃៅដទៃទៀត, អមនុស្សធម៌ ឬ បន្ទាបបន្ថោក ឬ ការដាក់ទណ្ឌកម្ម ឯកសារ UN Doc. No. A/61/259, ថ្ងៃទី១៤ ខែសីហា ឆ្នាំ ២០០៦ (ឧបសម្ព័ន្ធ២) ទំព័រ១៤ ដល់១៦ ។ សូមមើលការពិភាក្សានៃករណីនេះ, T. Thienel "អំពើទារុណកម្មរបស់បរទេស និង ភាពអាចទទួលយកបាននៃភស្តុតាង ។ សេចក្តីសម្រេចរបស់សភាជាន់ខ្ពស់ (House of Lords) នៅក្នុងករណី *A និង អ្នកដទៃទៀត តទល់ជាមួយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ* (លេខ ២)" នៅក្នុងទិន្នានុប្បវត្តិយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ ៤ (២០០៦) ៤១០ (ឧបសម្ព័ន្ធ ៨) ។

[23] មហាសន្និបាតអង្គការសហប្រជាជាតិ, ទារុណកម្ម និង ការប្រព្រឹត្តឃោរឃៅដទៃទៀត, អមនុស្សធម៌ ឬ បន្ទាបបន្ថោក ឬ ការដាក់ទណ្ឌកម្ម ឯកសារ UN Doc. No. A/61/259, ថ្ងៃទី១៤ ខែសីហា ឆ្នាំ ២០០៦ (ឧបសម្ព័ន្ធ២) ទំព័រ ១៧ ។

[24] សៀវភៅរបស់លោក Stephen Heder និង Brian D. Tittermore "ជនប្រាំពីរប្រឈមមុខនឹងការកាត់ទោស" ការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម" ភ្នំពេញ: DC-Cam 2004, ទំព័រ ២៨ ។

29. ប៉ុន្តែ ពួកគេស្នើសុំឱ្យមានការប្រើប្រាស់ឱ្យបានទូលំទូលាយនូវចម្លើយសារភាពដែលទទួលបានតាមរយៈការធ្វើទារុណកម្ម ច្រើនជាងអ្វីដែលអនុញ្ញាតដោយអនុសញ្ញាប្រឆាំងនឹងទារុណកម្ម ។ ពួកនេះស្នើសុំឱ្យពន្លាតការប្រើប្រាស់ចម្លើយសារភាព (i) ដើម្បីបង្ហាញពីអត្ថិភាពនៃឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្ត ក្រៅពីការធ្វើទារុណកម្ម (ii) ដើម្បីបង្ហាញពីគោលនយោបាយទូលំទូលាយរបស់ ប.ក.ក និង (iii) ជាភស្តុតាងតម្រុយសម្រាប់កិច្ចស៊ើបសួរបន្ត ។

30. ជាក់ស្តែង ការបកស្រាយបែបនេះ គឺគ្រាន់តែសម្រាប់ប្រើប្រាស់ការនិពន្ធសៀវភៅ "ជនប្រាំពីរនាក់ប្រឈមមុខនឹងការកាត់ទោស" ដោយសារតែអយ្យការបានពឹងផ្អែកលើសៀវភៅនោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ[25] និងការជាប់ពាក់ព័ន្ធរបស់លោក Stephen Heder ជាមួយ ក.ស.ច.ស និង ក.ស.ព ហេតុដូច្នេះ មេធាវីការពារស្នើសុំបដិសេធយ៉ាងច្បាស់ទៅលើវិធីសាស្ត្រនៃការបកស្រាយដែលបានលើកឡើងដោយលោក Stephen Heder ។

31. នៅក្នុងឃ្លាទីមួយ លោក Stephen Heder និង Tittemore លើកឡើងថា "ការពិចារណាទៅលើគោលនយោបាយដែលគួសបញ្ជាក់ពីអភិក្រមនៃអនុសញ្ញារបស់អង្គការសហប្រជាជាតិប្រឆាំងនឹងទារុណកម្ម អាចគាំទ្រដល់ការប្រើប្រាស់ចម្លើយសារភាពប្រហាក់ប្រហែលគ្នានេះដែលថា ឧក្រិដ្ឋកម្មទាំងឡាយ ក្រៅពីការធ្វើទារុណកម្ម រួមទាំងការសម្លាប់រង្គាលផង ត្រូវបានប្រព្រឹត្តឡើង"[26]។ ពួកគេលើកឡើងថា ចម្លើយសារភាពទាំងនេះអាចយកមកប្រើប្រាស់ជាភស្តុតាងប្រឆាំងនឹងចុងចោទ ដែលបានទទួលការផ្សព្វផ្សាយពីចម្លើយសារភាពទាំងនេះ ដើម្បីបង្ហាញថាពួកគេទំនងជាបានដឹងឮពីការសម្លាប់រង្គាលនេះ។ ពួកគេពិចារណាថា ការប្រើប្រាស់បែបនេះ "ស៊ីសង្វាក់គ្នាទៅនឹងអភិក្រមនៃអនុសញ្ញា អ.ស.ប ប្រឆាំងនឹងទារុណកម្ម"[27]។

---

[25] សូមមើលឧបសម្ព័ន្ធ ខ ដែលភ្ជាប់ជាមួយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ទំព័រ៥ 5 (ERN 00146888-000147014) ។ សូមមើលផងដែរនូវប្រភពដទៃទៀត ដែលត្រូវបានលើកឡើងដោយព្រះរាជអាជ្ញាដែលពឹងផ្អែកលើប្រភពនេះ ។ គ្រាន់តែជាវិធីបង្ហាញពីឧទាហរណ៍ សូមមើល: កាសែតភ្នំពេញប៉ុស្តិ៍ (16/1) "The Amnesia of Brother Number 2" លេខផ្សាយ ១២-២៥ ខែមករា ឆ្នាំ ២០០៧, (ERN 00081516-00081520).។

[26] Stephen Heder និង Brian D. Tittemore, (បេក្ខជនប្រាំពីរនាក់ដែលត្រូវប្រឈមមុខនឹងការចោទប្រកាន់ ។ ការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម") ភ្នំពេញ: DC-Cam ឆ្នាំ២០០៤ ទំព័រ៣០។

[27] Stephen Heder និង Brian D. Tittemore, (ជនប្រាំពីរនាក់ដែលត្រូវប្រឈមមុខនឹងការកាត់ទោស។ ការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម) "Seven Candidates for Prosecution. Accountability for the Crimes of the Khmer Rouge"។ ភ្នំពេញ: DC-Cam ឆ្នាំ២០០៤ ទំព័រ៣០។

32. ការបកស្រាយនេះអាចពង្រីកវិសាលភាពនៃការអនុវត្តមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងទារុណកម្ម (CAT)។ វាមិនគ្រាន់តែត្រូវបានប្រើប្រាស់ដើម្បីបង្ហាញអង្គហេតុថា អំពើទារុណកម្មត្រូវបានប្រព្រឹតឡើងប៉ុណ្ណោះទេ ប៉ុន្តែ ក៏ដើម្បីបង្ហាញថា ការដឹងឮពីការធ្វើទារុណកម្ម និងឧក្រិដ្ឋកម្មផ្សេងទៀត បានកើតមានចំពោះបុគ្គលមួយចំនួននៅក្នុងជួរបក្សកុម្មុយនីស្តកម្ពុជា។ មេធាវីការពារសូមលើកឡើងថា ពុំមានមូលដ្ឋានច្បាប់សម្រាប់ការបកស្រាយទូលំទូលាយបែបនេះទេ ហើយការប្រើប្រាស់បែបនេះ គឺមិនអាចទទួលយកបានឡើយ។

33. គំរូទីពីរដែលលោក Stephen Heder និង Brian D Tittemore ស្នើឡើងនោះ គឺដើម្បីបង្ហាញពីគោលនយោបាយទូលំទូលាយរបស់បក្សកុម្មុយនីស្តកម្ពុជា។ ពួកគេបានសរសេរបន្តទៀតថា:

> "ខណៈដែលឯកសារជាច្រើន ដែលចម្លើយសារភាពនៅ ស-២១ បានបញ្ជាក់នោះ តាមពិតទៅ គឺជាការមិនពិតទាំងស្រុង ចម្លើយសារភាពផ្តល់តៗគ្នានូវការយល់ឃើញយ៉ាងសំខាន់ចំពោះគោលនយោបាយឧក្រិដ្ឋដែលជាកម្មវត្ថុនៃរបាយការណ៍នេះ។ សំខាន់បំផុតនោះគឺ ចម្លើយសារភាពខ្លួនវាផ្ទាល់បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការអនុវត្តគោលនយោបាយទាំងនោះ ដែលជាចំនុចមួយអាចត្រូវបានពេញចិត្តទៅបានដោយការពិនិត្យមើលខ្លឹមសាររបស់ចម្លើយសារភាពទាំងនោះ"[28]។

34. ការបកស្រាយដែលបានលើកឡើងនេះ គឺលើសពីវិធីដែលបានលើកឡើងរួចទៅហើយទៅទៀត ហើយ វាប្រឆាំងដោយផ្ទាល់ទៅនឹងមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងទារុណកម្ម។ បញ្ហានេះនឹងបញ្ជាក់ជូនដូចខាងក្រោមនេះ។

35. វិធីទីបី និងចុងក្រោយបំផុត ដែលបានលើកឡើងដោយ Stephen Heder និង Brian D Tittemore គឺដើម្បីប្រើប្រាស់ភស្តុតាងដែលបានមកពីការធ្វើទារុណកម្ម ជាភស្តុតាងតម្រុយសម្រាប់ការស៊ើបសួរបន្តទៅទៀត។ ពួកគេសរសេរថា "វាអាចផ្តល់ឲ្យអ្នកស៊ើបអង្កេតនូវតម្រុយដែលអាចជឿទុកចិត្តបានទៅនឹងប្រភពដទៃទៀតនៃភស្តុតាង"[29]។ ហេតុអ្វីក៏គេមិនពន្យល់អំពីខ្លឹមសារដែល "អាចឲ្យជឿទុកចិត្តបាននោះ"? ជាថ្មីម្តងទៀត មេធាវីការពារក៏សូមលើកឡើងផងដែរថា ការប្រើប្រាស់ភស្តុតាង ដែលជាភស្តុតាងតម្រុយបែបនេះ គឺប្រាកដជាមិនអាចទទួលយកបានទេ ដោយហេតុថា តាមនិយមន័យ ខ្លឹមសាររបស់វានោះ គឺមិនអាចឲ្យជឿទុកចិត្តបានទេ។

---

[28] Stephen Heder និង Brian D. Tittemore, (ជនប្រាំពីរនាក់ដែលត្រូវប្រឈមមុខនឹងការកាត់ទោស។ ការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម) "Seven Candidates for Prosecution. Accountability for the Crimes of the Khmer Rouge"។ ភ្នំពេញ: DC-Cam ឆ្នាំ២០០៤ ទំព័រ៣០។

[29] Stephen Heder និង Brian D. Tittemore, (ជនប្រាំពីរនាក់ដែលត្រូវប្រឈមមុខនឹងការកាត់ទោស។ ការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម) "Seven Candidates for Prosecution. Accountability for the Crimes of the Khmer Rouge"។ ភ្នំពេញ: DC-Cam ឆ្នាំ២០០៤ ទំព័រ៣១។

## ៣.៦ លោក Michael Scharf: ការរំលោភទៅលើការសន្មតទុកជាមុនថាគ្មានទោស

36. នៅក្នុងអត្ថបទថ្មីៗរបស់គាត់ដែលពិភាក្សា ថាតើគួរមានអញ្ញត្រកម្មបែបលក្ខណៈពង្រីកចំពោះវិធានផ្តាច់មុខនៃភស្តុតាងដែលបានពីការធ្វើទារុណកម្ម ឬយ៉ាងណានោះ លោក Michael Scharf ទាញហេតុផលថា:

> "បញ្ហាសម្រាប់តុលាការកម្ពុជានោះគឺថា ភស្តុតាងនៅទួលស្លែង ត្រូវបានគេជឿជាក់ថា វាសំខាន់បំផុតក្នុងការបង្ហាញពីការទទួលខុសត្រូវក្នុងនាមជាថ្នាក់លើ និង/ឬ ការទទួលខុសត្រូវជាសហកម្មឧក្រិដ្ឋកម្មរួមរបស់មេដឹកនាំខ្មែរក្រហមមួយចំនួនតូចដែលកំពុងត្រូវបានជំនុំជម្រះក្តីដោយតុលាការនេះ។ បន្ថែមលើនេះទៅទៀត ភស្តុតាងនឹងតម្រូវឲ្យបង្ហាញថា ចុងចោទឆ្លើយតបចំពោះលក្ខខណ្ឌយុត្តាធិការរបស់តុលាការ ដែលដាក់កម្រិតការចោទប្រកាន់ទៅលើ "មេដឹកនាំជាន់ខ្ពស់" និង "អ្នកទទួលខុសត្រូវខ្ពស់បំផុត"[30]។

គាត់ក៏បានបន្ថែមទៀតថា:

> "ក្នុងពេលអវត្តមានភស្តុតាងជាឯកសារ ឬ ចម្លើយសាក្សីដែលភ្ជាប់ទៅនឹងចុងចោទដែលជាមេដឹកនាំខ្មែរក្រហមចំពោះការសម្លាប់រង្គាលណាមួយ ភស្តុតាងនៅមន្ទីរឃុំឃាំងទួលស្លែង គឺមានសារៈសំខាន់ណាស់សម្រាប់ការកាត់ទោសប្រកបដោយជោគជ័យនៅចំពោះមុខតុលាការកម្ពុជាមួយនេះ"[31]។

37.ម្យ៉ាងវិញទៀត លោក Scharf បានលើកឡើងនូវអញ្ញត្រកម្មជាក់លាក់មួយសម្រាប់ អ.វ.ត.ក ដោយហេតុថា ភស្តុតាងបែបនេះចាំបាច់នៅក្នុងការបង្ហាញពីពិរុទ្ធភាពរបស់ជនជាប់ចោទ ។ ក្នុងករណីពិសេសនេះ វាចាំបាច់បំផុតក្នុងការបង្កើតអញ្ញត្រកម្ម ចំពោះកាតព្វកិច្ចច្បាប់អន្តរជាតិ ប្រសិនបើមិនមានលទ្ធភាពបង្ហាញពីពិរុទ្ធភាពរបស់ពួកគេផ្សេង ក្រៅពីនេះបានទេ។ នេះគឺជាការរំលោភបំពានដ៏ពិតៗទៅលើសិទ្ធិរបស់ជនជាប់ចោទ ដែលត្រូវបានសន្មតជាមុនថាគ្មានទោស រហូតទាល់តែរកឃើញថាមានពិរុទ្ធភាព។

38. បន្ទាប់ពីការកំណត់នូវភាពចាំបាច់នៃការប្រើប្រាស់ភស្តុតាងបែបនេះ ក្នុងការអះអាងពីការផ្តន្ទាទោសចំពោះជនជាប់ចោទ លោក Scharf ពន្យល់ពីមូលហេតុដែលអាចធ្វើទៅបាន ដើម្បីទទួលយកភស្តុតាងបែបនេះ។ គាត់បានស្នើគំរូអញ្ញត្រកម្មចំនួនបី។

---

[30] M.P. Scharf, "Tainted Provenance: ប្រសិនបើអាច តើនៅពេលណាដែលភស្តុតាងនៃអំពើទារុណកម្មអាចទទួលយកបាន? When, If Ever, Should Torture Evidence Be Admissible?", in: 65 Wash & Lee L. Rev. 129 (Winter 2008), (ឧបសម្ព័ន្ធ ៥) កថាខណ្ឌ ១៣២។

[31] M.P. Scharf, "Tainted Provenance: ប្រសិនបើអាច តើនៅពេលណាដែលភស្តុតាងនៃអំពើទារុណកម្មអាចទទួលយកបាន? When, If Ever, Should Torture Evidence Be Admissible?", in: 65 Wash & Lee L. Rev. 129 (Winter 2008), (ឧបសម្ព័ន្ធ ៥) កថាខណ្ឌ ១៣៩។

39. ដំបូង គាត់ស្នើសុំឱ្យមានអញ្ញត្រកម្មសម្រាប់ការចោទសួរបឋម មានន័យថា ភស្តុតាងដែលទទួលបានមុនសក្តីកម្មដែលទទួលបានដោយការធ្វើទារុណកម្ម។ តាមពិតទៅ ប្រសិនបើរកឃើញថាភស្តុតាងបែបនេះ ទទួលបានដោយការធ្វើទារុណកម្ម នោះវាមិនស្ថិតនៅក្រោមមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្មទេ។ លោក Scharf បន្ថែមទៀតថា "តុលាការនេះមិនមានចំណាប់អារម្មណ៍ទៅលើចម្លើយសំខាន់ៗ ដែលផ្តល់ដោយអ្នកជាប់ឃុំឃាំងក្នុងអំឡុងពេលមានការធ្វើទារុណកម្មលើរូបកាយពិតៗនោះទេ"[32]។

40. បន្ទាប់មក លោក Scharf បន្តចូលទៅក្នុងការពិភាក្សាលំអិតពីកម្រិតនៃការធ្វើទារុណកម្ម និងការប្រព្រឹត្តយ៉ាងឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោក ឬទណ្ឌកម្ម ឱ្យស្ថិតនៅក្រោមមាត្រា ១៥[33]។ មេធាវីការពារសូមជំទាស់តវ៉ាចំពោះសុពលភាពនៃការវែកញែកបែបនេះ ហើយក្នុងករណីណាក៏ដោយ ការពិភាក្សាបែបនេះ គឺសម្រាប់តែអ្នកសិក្សាស្រាវជ្រាវប៉ុណ្ណោះ ដោយហេតុថា វាមិនអាចបង្កើតបានជាចរិតលក្ខណៈនៃអំពើទារុណកម្ម ដែលធ្វើទៅលើអ្នកជាប់ឃុំនៅមន្ទីរសន្តិសុខពាក់ព័ន្ធនឹងចម្លើយសារភាពដែលបានធ្វើឡើងរយៈពេលសាមសិបឆ្នាំកន្លងមកហើយនោះ។

41. ចុងបញ្ចប់ គាត់ពិភាក្សាទៅលើទ្រឹស្តីនៃភាពចាំបាច់ ដូចមានចែងក្នុងមាត្រា ២៥ នៃសេចក្តីព្រាងច្បាប់ស្តីពីការទទួលខុសត្រូវរបស់រដ្ឋ ដោយគណៈកម្មាធិការច្បាប់អន្តរជាតិ ដែលចែងថា:

> "១. រដ្ឋមិនអាចយកភាពចាំបាច់មកសំអាងជាមូលហេតុ ដើម្បីច្រានចោលកំហុសឆ្គងនៃអំពើមួយ ដែលមិនស្របទៅនឹងកាតព្វកិច្ចអន្តរជាតិរបស់រដ្ឋនោះបានទេ លើកលែងតែអំពើនោះ (ក) គឺជាមធ្យោបាយតែមួយគត់ សម្រាប់ឱ្យរដ្ឋនោះធានាការពារផលប្រយោជន៍ពិសេសប្រឆាំងទៅនឹងហានិភ័យធ្ងន់ធ្ងរ និង ហានិភ័យដែលហៀបនឹងកើតឡើង និង(ខ) មិនធ្វើឱ្យខូចខាតធ្ងន់ធ្ងរដល់ផលប្រយោជន៍ចាំបាច់របស់រដ្ឋនោះ ឬរដ្ឋទាំងឡាយណាដែលមានកាតព្វកិច្ចបែបនេះ ឬ របស់សហគមន៍អន្តរជាតិទាំងមូលទេ។
>
> ២. ក្នុងករណីណាក៏ដោយ រដ្ឋមិនអាចយកភាពចាំបាច់នេះមកសំអាងជាមូលហេតុ ដើម្បីច្រានចោលកំហុសឆ្គងបានទេ ប្រសិនបើ (ក) កាតព្វកិច្ចអន្តរជាតិមិនរាប់បញ្ចូលនូវលទ្ធភាពនៃការអះអាងពីភាពចាំបាច់នោះទេ (ខ) រដ្ឋបានចូលរួមទៅនឹងស្ថានភាពនៃភាពចាំបាច់នោះ"[34]។

---

[32] M.P. Scharf, "Tainted Provenance: ប្រសិនបើអាច តើនៅពេលណាដែលភស្តុតាងនៃអំពើទារុណកម្មអាចទទួលយកបាន? When, If Ever, Should Torture Evidence Be Admissible?", in: 65 Wash & Lee L. Rev. 129 (Winter 2008), (ឧបសម្ព័ន្ធ ៤) កថាខណ្ឌ ១៤០។

[33] M.P. Scharf, "Tainted Provenance: ប្រសិនបើអាច តើនៅពេលណាដែលភស្តុតាងនៃអំពើទារុណកម្មអាចទទួលយកបាន? When, If Ever, Should Torture Evidence Be Admissible?", in: 65 Wash & Lee L. Rev. 129 (Winter 2008), (ឧបសម្ព័ន្ធ ៤) កថាខណ្ឌ ១៤១ ដល់ ១៤៧។

[34] សេចក្តីព្រាងច្បាប់ស្តីពីការទទួលខុសត្រូវរបស់រដ្ឋ ដែលព្រាងឡើងដោយគណៈកម្មាធិការច្បាប់អន្តរជាតិ, ឯកសារ អ.ស.ប។

42. លោក Scharf ពិភាក្សាលើជម្រើសនេះដោយទាក់ទងទៅនឹងបញ្ហាដំបូង ដែលមិនទទួលបានពីការធ្វើទារុណកម្មតែប៉ុណ្ណោះ ដែលមេធាវីការពារមិនបដិសេធនោះទេ។ ប៉ុន្តែ មេធាវីការពារសូមលើកឡើងថា ការបកស្រាយទ្រឹស្តីនៃភាពចាំបាច់នេះ គឺជាមធ្យោបាយដើម្បីងាកចេញពីលក្ខខណ្ឌនៃមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងទារុណកម្ម និងផ្ទុយទៅនឹងគោលការណ៍ដែលមានចែងនៅក្នុងមាត្រានោះ។ នៅក្នុងការផ្តល់គំនិតយោបល់របស់ខ្លួនទៅលើមាត្រា ២៥ គណៈកម្មាធិការច្បាប់អន្តរជាតិដែលបានធ្វើសេចក្តីព្រាងច្បាប់នោះ បញ្ជាក់ថា [ពាក្យថា "ភាពចាំបាច់" (état de nécessité) ត្រូវបានយកមកប្រើប្រាស់ដើម្បីចង្អុលបង្ហាញពីករណីពិសេសទាំងនោះ ដែលជាមធ្យោបាយតែមួយគត់ ដែលរដ្ឋអាចការពារផលប្រយោជន៍ចាំបាច់ដែលត្រូវបានគំរាមកំហែងដោយហានិភ័យធ្ងន់ធ្ងរ និងហានិភ័យហៀបនឹងកើតឡើងនោះ ដែលក្នុងខណៈនេះ គឺមិនត្រូវបំពេញកាតព្វកិច្ចអន្តរជាតិផ្សេងៗទៀតដែលមានទម្ងន់ ឬភាពចាំបាច់ធូរស្រាលជាងនោះទេ]។ លោក Scharf កំណត់ "ហានិភ័យធ្ងន់ធ្ងរ និងហានិភ័យហៀបនឹងកើតឡើង" បែបនោះថាជា "ការផ្តន្ទាទោសប្រកបដោយជោគជ័យទៅលើអតីតមេដឹកនាំខ្មែរក្រហម"[35]។ ការបកស្រាយច្បាប់បែបនេះ គឺរំលោភទៅលើការសន្មតជាមុនថាគ្មានទោស ដែលត្រូវបានផ្តល់សិទ្ធិឲ្យជនជាប់ចោទ និងការដកហូតសិទ្ធិការពារខ្លួនរបស់គេ ដែលមានចែងក្នុងមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងទារុណកម្ម។

43. អញ្ញត្រកម្មទីពីរនៃមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងទារុណកម្ម ដែលលោក Scharf បានស្នើឡើង គឺទាក់ទងទៅនឹងភស្តុតាងដែលបានទទួលដោយភាគីទីបី។ សំណើនេះត្រូវបានច្រានចោលយ៉ាងច្បាស់ក្រឡែតនៅក្នុងរឿងក្តីនៅចក្រភពអង់គ្លេស[36] និងប្រទេសអាឡឺម៉ង់[37] ហើយតាមពិតទៅវាជាការរំលោភមាត្រា ១៥ ដែលមិនតម្រូវថា អាជ្ញាធរដែលទទួលបន្ទុកការចោទប្រកាន់បានប្រព្រឹត្តអំពើទារុណកម្មដោយខ្លួនឯងនោះទេ។ ទារុណកម្មប្រព្រឹត្តឡើងដោយអង្គភាពផ្សេងទៀតមិនប៉ះពាល់ដល់ភាពមិនគួរឲ្យទុកចិត្តបាននៃព័ត៌មានដែលបានទទួលនោះទេ។

---

[35] M.P. Scharf, "Tainted Provenance: ប្រសិនបើអាច តើនៅពេលណាដែលភស្តុតាងនៃអំពើទារុណកម្មអាចទទួលយកបាន? When, If Ever, Should Torture Evidence Be Admissible?", in: 65 Wash & Lee L. Rev. 129 (Winter 2008), (ឧបសម្ព័ន្ធ ៤) កថាខណ្ឌ ១៤៨ ដល់ ១៤៩។

[36] រឿងក្តីរបស់ A និង អ្នកដទៃទៀត តទល់នឹងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ, *(No. 2)* [2005] UKHL 71, [2005] 3 WLR 1249, URL address: www.parliament.the-stationery-office.co.uk/pa/ld200506/ldjudgmt/jd051208/aand.pdf.

[37] *Beschluss IV – 1/04 des Hanseatischen Oberlandesgericht Hamburg,* Neue Juristische Wochenschrift 2005 Heft 32 of 14 June 2005, referred to in UN General Assembly, Torture and other cruel, inhuman or degrading treatment or punishment, UN Doc (យោងមហាសន្និបាត អ.ស.ប, ទារុណកម្ម និងការប្រព្រឹត្តដែលឃោរឃៅអមនុស្សធម៌ ឬបន្ទាបបន្ថោក), ឯកសារលេខ A/61/259, ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៦ (ឧបសម្ព័ន្ធ ២) កថាខណ្ឌ ៤៦។

44. ក្នុងរឿងក្តីរបស់ចក្រភពអង់គ្លេសរវាង *A និង អ្នកដទៃទៀត* សភាជាន់ខ្ពស់ (House of Lords) បានសម្រេចថា ការច្រានចោលកាទទួលយកនេះ គឺមានលក្ខណៈទូលំទូលាយពេក។ ចៅក្រម Bingham បញ្ជាក់ថា "ការបកស្រាយបន្ថែមធ្វើឱ្យយល់ច្បាស់ពីលក្ខណៈដ៏ទូលំទូលាយនៃវិធានស្តីពីការច្រានចោលនេះ"[38]។ លោក Thienel យល់ឃើញថា ការបកស្រាយដោយការច្រានចោលភស្តុតាងផិតដាមដោយការធ្វើទារុណកម្មប្រព្រឹត្តឡើងដោយតតីយជន គឺសំអាងទៅលើសារតាប្រវត្តិសាស្ត្រ និងក្រុមការងាររៀបចំ (*travaux préparatoires*) មាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងទារុណកម្ម[39]។

45. នៅក្នុងការជជែកតវ៉ាលើកទីបី និងចុងក្រោយបង្អស់របស់គាត់ សម្រាប់ការបកស្រាយតាមន័យទូលាយនៃមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងទារុណកម្ម លោក Scharf ស្នើសុំឱ្យពង្រីកការបកស្រាយ ដើម្បីបង្គលក្ខណៈដល់ការប្រើប្រាស់ភស្តុតាងបែបនេះ ដោយមិនមែនគ្រាន់តែប្រឆាំងនឹងអ្នកធ្វើទារុណកម្ម ដែលត្រូវបានចោទប្រកាន់ប៉ុណ្ណោះទេ ប៉ុន្តែ ក៏ថែមទាំងប្រឆាំងនឹងថ្នាក់លើដែលត្រូវបានចោទប្រកាន់នោះដែរ។ ជាថ្មីម្តងទៀត គាត់ស្នើសុំឱ្យប្រើប្រាស់ខ្លឹមសារនៃកំណត់ហេតុបែបនោះ ដែលត្រូវបានហាមឃាត់ដោយមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងទារុណកម្ម[40]។

46. លោក Scharf បញ្ជាក់ថា ការច្រានចោលភស្តុតាងបែបនេះ អាចនាំឱ្យឈានដល់ការរំខាន ឬនាំឱ្យមានលទ្ធផលមិនសមហេតុផល[41] ប៉ុន្តែ គាត់មិនបានលើកឡើង ថាតើគេអាចធ្វើយុត្តិកម្មចំពោះការប្រើប្រាស់ខ្លឹមសារនៃភស្តុតាងដែលសន្មតថាមិនអាចជឿទុកចិត្ត បានដោយរបៀបណា

---

[38] រឿងក្តីរបស់ A និង អ្នកដទៃទៀត តទល់នឹងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ, *(No. 2)* [2005] UKHL 71, [2005] 3 WLR 1249, URL address: www.parliament.the-stationery-office.co.uk/pa/ld200506/ldjudgmt/jd051208/aand.pdf, កថាខណ្ឌ ៣៥។ សូមមើលការពិភាក្សាទៅលើការប្រើប្រាស់ភស្តុតាងដែលប្រឡូកប្រឡាក់ នៅក្នុងតុលាការរបស់រដ្ឋដែលមិនបានពាក់ព័ន្ធជាមួយអំពើទារុណកម្ម, T. Thienel, "ការទទួលយកភស្តុតាងដែលបានមកដោយការធ្វើទារុណកម្ម នៅក្រោមច្បាប់អន្តរជាតិ" នៅក្នុងព្រឹត្តិប័ត្រច្បាប់អន្តរជាតិអឺរ៉ុប ១៧(២០៦)៣៤៩ (ឧបសម្ព័ន្ធ ៧) ទំព័រ ៣៥៩ ។

[39] T. Thienel, "ការទទួលយកភស្តុតាងដែលបានមកដោយការធ្វើទារុណកម្ម នៅក្រោមច្បាប់អន្តរជាតិ" នៅក្នុងព្រឹត្តិប័ត្រច្បាប់អន្តរជាតិអឺរ៉ុប ១៧(២០០៦)៣៤៩ (ឧបសម្ព័ន្ធ ៧) ទំព័រ ៣៥៧ ។

[40] M.P. Scharf, "Tainted Provenance: ប្រសិនបើអាច តើនៅពេលណាដែលភស្តុតាងនៃអំពើទារុណកម្មអាចទទួលយកបាន? When, If Ever, Should Torture Evidence Be Admissible?", in: 65 Wash & Lee L. Rev. 129 (Winter 2008), (ឧបសម្ព័ន្ធ ៤) កថាខណ្ឌ ១៤៨ ដល់ ១៥៩។

[41] M.P. Scharf, "Tainted Provenance: ប្រសិនបើអាច តើនៅពេលណាដែលភស្តុតាងនៃអំពើទារុណកម្មអាចទទួលយកបាន? When, If Ever, Should Torture Evidence Be Admissible?", in: 65 Wash & Lee L. Rev. 129 (Winter 2008), (ឧបសម្ព័ន្ធ ៤) កថាខណ្ឌ ១៤៨ ដល់ ១៥៩។

នោះទេ។ ប្រាកដណាស់ថា វាជាមូលហេតុមួយក្នុងចំណោមមូលហេតុជាមូលដ្ឋានពីរ សម្រាប់ការតាក់តែងដ៏តឹងរ៉ឹងនៃមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងទារុណកម្ម ដើម្បីច្រានចោលការសំអាងទៅលើខ្លឹមសារនៃកំណត់ហេតុផ្តល់ចម្លើយដែលមិនអាចជឿទុកចិត្តបាន ដែលបានមកពីការធ្វើទារុណកម្ម។

47. ការកម្រិតការប្រើប្រាស់ចម្លើយសារភាពដើម្បីបង្ហាញថា អំពើទារុណកម្មដែលបានប្រព្រឹត្តត្រូវបានអនុញ្ញាតដោយអនុសញ្ញាប្រឆាំងនឹងទារុណកម្ម។ ការអនុវត្តចម្លើយសារភាពណាមួយបែបនោះក្នុងលក្ខណៈទូលំទូលាយ មិនមែនគ្រាន់តែរំលោភទៅលើអនុសញ្ញានេះប៉ុណ្ណោះទេ តែថែមទាំងរំលោភបំពានដល់សិទ្ធិរបស់ជនត្រូវចោទ ដែលត្រូវបានសន្មតទុកជាមុនថាគ្មានទោស ដរាបណាមិនទាន់រកឃើញថាមានពិរុទ្ធភាពនោះទេ។ ប្រសិនបើអញ្ញត្រកម្មចំពោះកាតព្វកិច្ចអន្តរជាតិ ត្រូវបានអនុញ្ញាតដើម្បីសម្របសម្រួលដល់ការចោទប្រកាន់ និងការផ្តន្ទាទោសទៅលើប្រភេទមនុស្សជាក់លាក់ណាមួយមែន នោះវាជាការបំពារបំពាន ទៅលើបទដ្ឋាននៃភាពត្រឹមត្រូវដែលបានទទួលស្គាល់ដែលបានបង្កើតឡើងជាច្រើនឆ្នាំមកហើយនោះ។

## ៣.៧ <u>សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌</u>

48. ដោយការទទួលយកភស្តុតាងបានមកដោយការធ្វើទារុណកម្ម នោះសិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ក៏ត្រូវបានរំលោភផងដែរ។ របាយការណ៍របស់ អ.ស.ប ដែលបានលើកមកមុននេះថ្លែងថា: ភាពសមហេតុផលដែលនៅពីក្រោយការច្រានចោលរបស់មាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងទារុណកម្មមានពីរផ្នែក: ទីមួយ ព័ត៌មានទួលបានដោយការធ្វើទារុណកម្ម គឺមិនអាចជឿទុកចិត្តបានទេ និងទីពីរ ការហាមឃាត់ចំពោះការប្រើប្រាស់ភស្តុតាងដែលបានពីការធ្វើទារុណកម្ម ត្រូវចូលរួមចំណែកក្នុងការទប់ស្កាត់ការអនុវត្តបែបនេះ[42]។

49. សទិសភាពដែលលោក Scharf លើកឡើងរវាងទិន្នន័យសុខាភិបាល ដែលវេជ្ជបណ្ឌិតណាហ្ស៊ី (Nazi) ទទួលបានដោយខុសច្បាប់ និងស្ថានភាពដែលបានលើកឡើង គឺខុសគ្នា និងមិនជាប់ពាក់ព័ន្ធ

---

[42] គណៈកម្មាធិការប្រឆាំងនឹងទារុណកម្ម សេចក្តីសន្និដ្ឋាន និងអនុសាសន៍របស់គណៈកម្មាធិការប្រឆាំងនឹងទារុណកម្ម: កម្ពុជា ចុះថ្ងៃ ទី២៧ ឧសភា ឆ្នាំ២០០៣ ឯកសារលេខ CAT/C/CR/30/2 (សេចក្តីសន្និដ្ឋានពីការសង្កេតការណ៍/ការផ្តល់យោបល់), URL address: <u>http://www.unhchr.ch/tbs/doc.nsf/(Symbol)/CAT.C.CR.30.2.En?OpenDocument</u>, កថាខណ្ឌ ៤៥។

នោះទេ ដោយហេតុថា ទិន្នន័យសុខាភិបាលដែលគាត់សំអាង ចាត់ទុកថាគួរឱ្យទុកចិត្តបាន[43]។ លោក Scharf មិនបានលើកឡើងពីបញ្ហាដ៏សំខាន់នៃកង្វះភាពគួរឱ្យទុកចិត្តបាននៃឯកសារដែលទទួលបានពីមកការធ្វើទារុណកម្ម។ នៅទំព័រ ១៦៩ នៃអត្ថបទរបស់គាត់លើកឡើងថា ភស្តុតាងបានមកពីការធ្វើទារុណកម្មគឺ "ជារឿយៗ មិនអាចជឿទុកចិត្តបានទេ" ប៉ុន្តែ ឯកសារជាក់លាក់ពីមន្ទីរឃុំឃាំងទួលស្លែងលើកឡើងពី "កម្រិតទទួលខុសត្រូវខ្ពស់មួយ"។ គាត់មិនបានពន្យល់ថាហេតុអ្វីបានជាភស្តុតាងជាក់លាក់ដែលគួរឱ្យជឿបានបែបនោះ ខុសពីភស្តុតាងដទៃទៀតដែលទទួលបានមកពីការធ្វើទារុណកម្មរបៀបណានោះទេ។

50. បញ្ហានៃការមិនគួរឱ្យជឿទុកចិត្តបាននៃភស្តុតាង និងបច្ច័យដែលជាប់មកជាមួយភស្តុតាងបែបនេះទៅលើសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ក៏ត្រូវបាន Tobias Thienel លើកឡើងនៅក្នុងអត្ថបទរបស់គាត់ស្តីពីការបកស្រាយមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងទារុណកម្មផងដែរ[44]។

## IV. សេចក្តីសន្និដ្ឋាន

51. មេធាវីការពារសូមលើកឡើងថា យោងតាមស្មារតីនៃកម្មវត្ថុនិងគោលបំណងរបស់មាត្រាដូចដែលបានចែងនៅក្នុងមាត្រា៣១ នៃអនុសញ្ញាទីក្រុងវីយែនស្តីពីច្បាប់សន្ធិសញ្ញា។ ការបកស្រាយទូលំទូលាយទៅលើមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងទារុណកម្ម ដូចដែលលោក Stephen Heder និងនិពន្ធដទៃទៀតបានលើកឡើង គឺមិនស៊ីសង្វាក់គ្នាទៅនឹងអត្ថន័យធម្មតានៃបទប្បញ្ញត្តិនេះទេ ។

52. ផ្ទុយទៅនឹងការពិត ការបកស្រាយមាត្រា ១៥ ក្នុងន័យទូលាយដែលបានស្នើឡើង ក៏បានលើកឡើងផងដែរថា មិនមានការពិភាក្សាទៅលើពាក្យពេចន៍ពិតប្រាកដនៃបទប្បញ្ញត្តិនោះ ដូចបានចង្អុលបង្ហាញដោយលោក Thienel ដែលបញ្ជាក់ថា ការបកស្រាយវិធានច្រានចោល ដោយការពង្រីកទៅលើបុគ្គលទាំងឡាយក្រៅពីជនរងគ្រោះនៃអំពើទារុណកម្ម គឺត្រូវបានសំអាងទៅលើសារតាប្រវត្តិ

[43] M.P. Scharf, "Tainted Provenance: ប្រសិនបើអាច តើនៅពេលណាដែលភស្តុតាងនៃអំពើទារុណកម្មអាចទទួលយកបាន? When, If Ever, Should Torture Evidence Be Admissible?", in: 65 Wash & Lee L. Rev. 129 (Winter 2008), (ឧបសម្ព័ន្ធ ៤) កថាខណ្ឌ ១៦២ ដល់ ១៦៨។

[44] T. Thienel, "ការទទួលយកភស្តុតាងដែលបានមកដោយការធ្វើទារុណកម្ម នៅក្រោមច្បាប់អន្តរជាតិ" នៅក្នុងព្រឹត្តិប័ត្រច្បាប់អន្តរជាតិអឺរ៉ុប ១៧(២០០៦)៣៤៩ (ឧបសម្ព័ន្ធ ៧) ទំព័រ ៣៥៨ ដល់ ៣៥៩ ។

សាស្ត្រ និងក្រុមការងាររៀបចំ (*travaux préparatoires*) មាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងទារុណកម្ម[45]។

53. គេអាចសន្និដ្ឋានទៅលើមូលដ្ឋាននៃកាតព្វកិច្ចក្រោមច្បាប់កម្ពុជា និងកាតព្វកិច្ចក្រោមច្បាប់អន្តរជាតិថា វិធានច្រានចោលនៃមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងទារុណកម្មគួរតែអនុវត្តចំពោះដំណើរការនីតិវិធីសព្វថ្ងៃ ហើយភស្តុតាងដែលទទួលបានដោយការធ្វើទារុណកម្ម ត្រូវប្រកាសថា មិនអាចទទួលយកបានទេនៅក្នុងដំណើរការនីតិវិធីសព្វថ្ងៃនេះ។

54. មិនគួរមានភាពខុសគ្នានៅក្នុងការប្រើប្រាស់មាត្រានេះ ជាភស្តុតាងជាក់ស្តែងនៅក្នុងសវនាការ ឬជាភស្តុតាងតម្រុយនៅក្នុងដំណាក់កាលស៊ើបសួរនោះទេ ដោយសារថា ការបដិសេធចំពោះការប្រើប្រាស់មាត្រានេះ គឺពាក់ព័ន្ធទៅនឹងការមិនគួរឲ្យជឿទុកចិត្តបាននៃភស្តុតាង ដែលទាក់ទងនៅគ្រប់ដំណាក់កាលនៃដំណើរការនីតិវិធីទាំងមូល។

55. ភាពសមហេតុផលនៅពីក្រោយការរឹតត្បិតទៅលើការប្រើប្រាស់នៃកំណត់ហេតុផ្តល់ចម្លើយដែលបានមកពីការធ្វើទារុណកម្ម គឺសមហេតុផល។ ខ្លឹមសារនៃកំណត់ហេតុបែបនេះ មិនអាចយកមកប្រើប្រាស់បានទេ បើទោះបីកំណត់ហេតុទាំងនោះ ជាកំណត់ពិតប្រាកដក៏ដោយ។ ចំនុចនេះហើយដែលពិតជាផ្ទុយទៅនឹងការប្រើប្រាស់ដ៏ទូលំទូលាយនៃកំណត់ហេតុទាំងនោះ ដូចដែលលោក Stephen Heder និង Tittemore បានលើកឡើង ។ លក្ខណៈតែមួយគត់ដែលភស្តុតាងទាំងនោះអាចត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់បាន គឺដើម្បីបង្ហាញថា ទារុណកម្មត្រូវបានប្រព្រឹតឡើង និងប្រឆាំងតែអ្នកធ្វើទារុណកម្មប៉ុណ្ណោះ ដូចដែលបានចែងយ៉ាងច្បាស់នៅក្នុងមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងទារុណកម្ម។

## V. **សំណូមពរ**

56. សម្រាប់ហេតុផលដែលបានលើកឡើងខាងលើ មេធាវីការពារសូមសំណូមពរដោយក្តីគោរពឲ្យ:

(i) ចាត់ទុកថា មិនអាចទទួលយកបានទេ ចំពោះភស្តុតាងទាំងឡាយណា ឬឯកសារផ្សេងទៀតដែលទទួលបាន ឬដែលអាចនឹងទទួលបានមកពីការប្រើប្រាស់អំពើទារុណកម្ម ក្រៅតែពីការបង្ហាញថាកំណត់ហេតុផ្តល់ចម្លើយជាក់លាក់មួយត្រូវបានធ្វើឡើងដោយការធ្វើទារុណកម្ម និងប្រឆាំងតែអ្នកធ្វើទារុណកម្មប៉ុណ្ណោះ រួមទាំង ប៉ុន្តែ មិនកម្រិតត្រឹមតែ:

---

[45] T. Thienel, "ការទទួលយកភស្តុតាងដែលបានមកដោយការធ្វើទារុណកម្ម នៅក្រោមច្បាប់អន្តរជាតិ" នៅក្នុងព្រឹត្តិប័ត្រច្បាប់អន្តរជាតិអឺរ៉ុប ១៧(២០០៦)៣៤៩ (ឧបសម្ព័ន្ធ ៧) ទំព័រ ៣៥៧។

(ក) ឯកសារលេខ D3/ឧបសម្ព័ន្ធ គ (៥- ចម្លើយសារភាព)[46]

(ខ) ឯកសារលេខ D82 (ឯកសារបានពីមន្ទីរឃុំឃាំង)[47]

(គ) ឯកសារលេខ D43/ឧបសម្ព័ន្ធ គ (ឯកសារបានពីមជ្ឈមណ្ឌលឯកសារកម្ពុជា)[48]

(ii) ទប់ស្កាត់ការប្រើប្រាស់កំណត់ហេតុផ្តល់ចម្លើយបែបនោះ តាមមធ្យាបាយណាមួយ ក្រៅពីអ្វីដែលបានលើកឡើងនៅក្នុងចំនុច (i) និង (ii) ខាងលើ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ២០០៩

**លោក ផាត់ ពៅសៀង**

**កញ្ញា Diana ELLIS, QC**

សហមេធាវីរបស់អ្នកស្រី អៀង ធីរិទ្ធ

[46] ឯកសារលេខ D3, ឧបសម្ព័ន្ធ គ - ឯកសារភស្តុតាងដទៃទៀត, ឯកសារភ្ជាប់ជាឧបសម្ព័ន្ធ ERN 00141524-00141652, ទំព័រពាក់ព័ន្ធ ១៣ ដល់ ២៨ ។

[47] ឯកសារលេខ D82, ដីកាចាត់ឲ្យស៊ើបសួរជំនួស ចុះថ្ងៃទី២៩ ខែមករា ២០០៨, ERN 00173193-00173194, ព្រមទាំងឧបសម្ព័ន្ធ និងរបាយការណ៍ស្តីពីដីកាចាត់ឲ្យស៊ើបសួរជំនួសទាំងអស់ ពាក់ព័ន្ធនឹងឯកសារលេខ D82។

[48] ឯកសារលេខ D43, ដីកាចាត់ឲ្យស៊ើបសួរជំនួស ចុះថ្ងៃទី៧ ខែធ្នូ ២០០៧, ERN 00156491-00156492, ព្រមទាំងឧបសម្ព័ន្ធ និងរបាយការណ៍ស្តីពីដីកាចាត់ឲ្យស៊ើបសួរជំនួសទាំងអស់ ពាក់ព័ន្ធនឹងឯកសារលេខ D43។